**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៩០៤/២២-១១-២០០៦

សាលដីកា
លេខ:៨៨(ជ)/២២-៨-២០០៨

# ឈ្មោះប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២២-៨-២០០៨ ដែលមានសមាសភាពដូចតទៅ :

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៩០៤ ចុះថ្ងៃទី២២-១១-២០០៦ រវាង :

-ជនជាប់ចោទឈ្មោះ [redacted] ឌី ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស កើតនៅភូមិក្រាំងឬស្សី ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន (ជាដើមបណ្តឹងឧទ្ធរណ៍) ។

ចាប់ខ្លួនថ្ងៃទី៣១-៥-២០០៥ ឃុំខ្លួនថ្ងៃទី០៦-៦-២០០៥

មានមេធាវីការពារឈ្មោះ [redacted] គឹមសេង

ត្រូវចោទពីបទ : ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៦-៥-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៦,៥៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសបទឧក្រិដ្ឋ និង ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់គ្រឿងអគ្គិសនី ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] (ជាចុងបណ្តឹងឧទ្ធរណ៍) ។



Scanned with CamScanner

ដែលមានដំណើររឿងដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី២៦-៥-២០០៥ របស់ឈ្មោះ [redacted] ចន្ធា បានប្តឹងពីចោរប្លន់ចំនួន៣នាក់ ប្រដាប់ដោយអាវុធខ្លីម៉ាកK៥៩មួយដើម បានប្លន់យកម៉ូតូខ្លួនមួយគ្រឿងម៉ាកC១២៥ពណ៌ខ្មៅ ស៊េរី២០០៥ គ្មានផ្លាកលេខ លេខតួ: ND១២៥ M៨០០៧៩២៩៧. លេខម៉ាស៊ីន:ND១២៥ ME៨០៧៩២៩៧ កាលពីថ្ងៃទី២៦-៥-២០០៥ វេលាម៉ោង ១៨:៣៥នាទី ខ្លួនបានឌុបប្រពន្ធ និង កូនប្រុសខ្លួនម្នាក់តាមផ្លូវលេខ១៦៣ មកជើង ពេលមកដល់ចំណុចមុខផ្ទះលេខ៣៧៦ សង្កាត់អូឡាំពិក ខណ្ឌចំការមន ស្រាប់តែមានម៉ូតូមួយគ្រឿងជិះស្របម៉ូតូខ្លួន ហើយមានគ្នាបីនាក់ជិះកៀរម៉ូតូខ្លួនបណ្តាលឱ្យដួល ហើយជនល្មើសម្នាក់បានស្រែកគំរាមខ្លួនឱ្យចេញៗ រួចបាញ់ឡើងលើមួយគ្រាប់( អាវុធជនល្មើសមានគកាណុង) ក្រម៉េពណ៌ស ហើយជនល្មើសម្នាក់ទៀត បានលើកម៉ូតូខ្លួនបើក ហើយជនល្មើសកាន់អាវុធឡើងជិះពីក្រោយបើកទៅទិសខាងជើង ជាមួយម៉ូតូម៉ាកC១២៥ពណ៌ខ្មៅ មិនច្បាស់ស៊េរីបាត់ទៅ ។

-ជនជាប់ចោទឈ្មោះ [redacted] នី ឆ្លើយនៅចៅក្រមស៊ើប. នៅអយ្យការ និង នគរបាលថា: ខ្លួនធ្លាប់បានប្លន់ម៉ូតូចំនួន០៣លើកមកហើយ មានគ្នាចំនួន០៣នាក់ អ្នកមានអាវុធឈ្មោះ ខឹរនោរ(K៥៩) នៅពេលប្លន់ម្តងៗឈ្មោះ ខឹរនោរជាអ្នកភ្ជង់កាំភ្លើង ខ្លួនជាអ្នកឡើងជិះម៉ូតូដែលភ្ជង់បាននោះ នៅពេលខ្លួនប្លន់ម៉ូតូC១២៥ ចុងក្រោយនេះ នៅមុំអូឡាំពិកពណ៌ខ្មៅ ស៊េរី២០០៥ តែសមត្ថកិច្ចចាប់ខ្លួនបានតែម្តង ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] នី ឆ្លើយពេលសវនាការថា: ប៉ូលីសចាប់ខ្លួនពីបទ:បំផ្លិចបំផ្លាញផ្ទះគេទៅដល់នគរបាលគេវាយខ្ញុំខ្លួនឱ្យឆ្លើយថា ប្លន់ម៉ូតូគេ ម៉ូតូនោះគឺជាម៉ូតូរបស់ខ្លួនទេ ខ្លួនបានទិញចំនួន៧៥០ដុល្លា ។

-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ធា ឆ្លើយពេលសវនាការថា: កាលពីថ្ងៃទី២៦-៥-២០០៥ វេលាម៉ោង៦ល្ងាច ខ្លួនជិះម៉ូតូជ១២៥ពណ៌ខ្មៅ តាមផ្លូវលេខ១៦៣ មកដល់មុខផ្ទះលេខ៣៧៦ សង្កាត់អូឡាំពិក ស្រាប់តែឃើញជនល្មើសមានគ្នា០៣នាក់ មានអាវុធខ្លីមួយដើមម៉ាកK៥៩ ជិះម៉ូតូម៉ាកC១២៥ពណ៌ខ្មៅ ជិះមកកៀរម៉ូតូខ្លួនឱ្យឈប់ ហើយបានប្លន់យកម៉ូតូខ្លួនទៅបាត់ទៅ នៅថ្ងៃទី០២-៦-២០០៥ ខ្លួនបានទទួលម៉ូតូខ្លួនពីនគរបាលវិញ ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី៣១-៥-២០០៥ របស់ប៉ុស្តិ៍ខណ្ឌដង្កោ ។(ឯកសារ.១)

-បានឃើញប្លង់កើតហេតុ ចុះថ្ងៃទី២៧-៥-២០០៥ របស់ប៉ូលីស ។(ឯកសារ.១)

-បានឃើញរបាយការណ៍ ចុះថ្ងៃទី០២-៦-២០០៥ របស់ប៉ូលីស ។(ឯកសារ.១)

-បានឃើញដីកាឃុំខ្លួនលេខ:៥៩២ ចុះថ្ងៃទី០៦-៦-២០០៥ របស់ចៅក្រមស៊ើបអង្កេត ឃុំខ្លួនឈ្មោះ [redacted] នី ។ (ឯកសារ.៦)

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:១៥១(ង) ចុះថ្ងៃទី១៦-១២-២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] នី ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយ:ពេល០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ដោយគិតបន្តពីសាលក្រមព្រហ្មទណ្ឌលេខ:១៦១(ឈ) ចុះថ្ងៃទី០២-១២-២០០៥ ពីបទ:ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៦-៥-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



Scanned with CamScanner

២-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ សម្រេចទុកពេលប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី០១-៧-២០០៨ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ធី (ចូល)

-ដើមបណ្តឹងឈ្មោះ [redacted] មន្នា (មិនចូល)

-មេធាវីការពារជនជាប់ចោទ [redacted] គីមសេង (ចូល)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និង សង្ខេបរឿងជូនអង្គសវនាការ

-ស.ឆ: [redacted] ធី : ខ្ញុំមិនបានប្លន់ម៉ូតូនៅថ្ងៃ២៦-៥-២០០៥ ទេ ខ្ញុំទិញម៉ូតូសេ១២៥ ពណ៌ខ្មៅ ខ្ញុំទិញពីឈ្មោះ [redacted] រ៉ាន់ ។ នៅតុលាការគេអត់វៃខ្ញុំ ពេលនោះមានប៉ូលីសម្នាក់មកបង្ខំខ្ញុំ ។ ពេលនោះមានបញ្ហា គេក៏ចាប់ខ្ញុំនៅផ្ទះជួល ។ ខ្ញុំគ្មានកាំភ្លើងទេ ។

-ស.ឆ: មានបញ្ហានោះគឺប្អូនថ្លៃខ្ញុំយកកង់ឡានដាក់នៅផ្ទះជួល ពេលនោះបាត់កង់ឡាន ថ្ងៃទី២៥-៥-២០០៥ ។

ស.ឆ: ច្រកចេញមានពីរច្រកចេញមួយតូច មួយធំ ។ ពេលបាត់កង់ឡានប្អូនថ្លៃខ្ញុំឡូឡា ពេលនោះប៉ូលីសមករករឿងខ្ញុំ ។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាឱ្យខ្លួនបានរួចផុតពីបទចោទប្រកាន់ នៃអំពើប្លន់ ។

## តំណាងមហាអយ្យការសន្និដ្ឋានថា

មានពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទ [redacted] ធី ពីបទៈប្លន់ ប្រាកដមែន ។

តំណាងមហាអយ្យការ សំរេចៈ

-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២-០១-២០០៦ របស់ជនជាប់ចោទ [redacted] ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:១៥១(ង) ចុះថ្ងៃទី១៦-១២-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ ។

-មេធាវី [redacted] គីមសេង ធ្វើសេចក្តីសន្និដ្ឋានៈ ក្នុងរឿងនេះ គឺកូនក្តីខ្ញុំមិនបានប្រព្រឹត្តដូចការចោទរបស់ព្រះរាជអាជ្ញាទេ ពីព្រោះថ្ងៃកើតហេតុនោះ កូនក្តីខ្ញុំបានទៅធ្វើបុណ្យសពឪពុកមា នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ គឺកូនក្តីខ្ញុំបានចូលប្រព្រឹត្តអំពើប្លន់នោះទេ ។ តាងនាមខ្ញុំជាមេធាវីការពារជនជាប់ចោទ [redacted] ធី សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាឱ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទ និង សូមក្រុមប្រឹក្សាជំនុំជម្រះ បដិសេធសាលក្រមព្រហ្មទណ្ឌលេខ:១៥១(ង) ចុះថ្ងៃទី១៦-១២-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ ចោលជាអសារបង់ ។

១៦៥



Scanned with CamScanner

## សាលាឧទ្ធរណ៍

**យល់ឃើញថា :**

-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២-០១-២០០៦ របស់ជនជាប់ចោទ [redacted] ឌី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមបញ្ញត្តិមាត្រា១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-ពាក្យសុំការពារក្តី ចុះថ្ងៃទី២៨-០១-២០០៨ របស់មេធាវី [redacted] គឹមសេង ការពារជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ពាក្យសុំទទួលស្គាល់មេធាវី [redacted] ចំរើន ចុះថ្ងៃទី១៦-៧-២០០៧ ការពារជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-តាមរបាយការណ៍ប៉ុស្តិ៍នគរបាលអូឡាំពិក ចុះថ្ងៃទី២៧-៥-២០០៥ បញ្ជាក់ថា នៅថ្ងៃទី២៦-៥-២០០៥ ម៉ោង៨:៣៥នាទី នៅមុខផ្ទះ៣៧៦ ផ្លូវ១៦៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន មានអំពើប្លន់ម៉ូតូC១២៥ ស៊េរី២០០៥ មួយគ្រឿង ពីជនរងគ្រោះ [redacted] ចន្ធា ដោយជនល្មើស៣នាក់មានអាវុធកា៥៩ មួយដើម កាណុងក្រហម ជិះម៉ូតូC១២៥ ពណ៌ខ្មៅ ក្នុងពេលដែលជនរងគ្រោះកំពុងជិះម៉ូតូឌុបប្រពន្ធ និង កូនម្នាក់ ។ ជនល្មើសជិះគៀរម៉ូតូជនរងគ្រោះឱ្យដួល រួចជនម្នាក់យកកាំភ្លើងភ្ជង់ ហើយបាញ់ឡើងលើ១គ្រាប់ និង ម្នាក់ទៀតលើកម៉ូតូជិះចេញទៅ ។

-តាមចម្លើយជនជាប់ចោទ [redacted] ឌី ថា ខ្លួននឹងគូកនបានប្លន់ម៉ូតូជ១២៥ ពណ៌ខ្មៅ១គ្រឿង នៅថ្ងៃទី២៦-៥-២០០៥ ត្រង់មុខផ្ទះ៣៧៦ ផ្លូវ១៦៣ សង្កាត់អូឡាំពិក ។ ចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយជនរងគ្រោះឈ្មោះ [redacted] ចន្ធា ដែរ ។

-សាលក្រមព្រហ្មទណ្ឌលេខ:១៥១(ជ) ចុះថ្ងៃទី១៦-១២-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២-០១-២០០៦ របស់ជនជាប់ចោទ [redacted] ឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយខាសគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:១៥១(ជ) ចុះថ្ងៃទី១៦-១២-២០០៥ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ ។

-បន្តឃុំខ្លួនជនជាប់ចោទ ។

៣-សាលដីកានេះជំនុំជម្រះ ~~និង~~ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។ ១៦៦

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ០២ ខែ ៤ ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]